ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៧៣៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ លើលិខិតលេខ ១៨៨ សហវ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំរៀបចំនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Doun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវ នីតិវិធីគយពិសេស សម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៣
- សភាពាណិជ្ជកម្មកម្ពុជា

  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធ

*នៃប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៨*

*របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពី*

## នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស

### ១. គោលបំណង និងវិសាលភាព

ក្នុងគោលបំណងដើម្បីពង្រឹងនូវភាពប្រកួតប្រជែង និងការទាក់ទាញវិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះតំបន់សេដ្ឋកិច្ចពិសេស កិច្ចសម្រួលពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងនីតិវិធីគយ ទាមទារឲ្យមានការអនុវត្តនូវនីតិវិធីគយពិសេសមួយដាច់ដោយឡែក និងមានយន្តការត្រួតពិនិត្យផ្លូវស្រាលជាងមាត់ច្រកធម្មតា ដើម្បីសម្រួលដល់ការដឹកជញ្ជូនចេញ-ចូលក្នុងតំបន់ ។ នីតិវិធីគយពិសេសនេះ សម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ដែលកំពុងដំណើរការ និងតំបន់ដែលគ្រោងនឹងដំណើរការនាពេលខាងមុខ ។

### ២. និយមន័យ

តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ដែលប្រមូលផ្ដុំនូវវិស័យឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចមាន តំបន់ឧស្សាហកម្មទូទៅ ឬតំបន់ផលិតកែច្នៃនាំចេញ ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍ ។ បែបបទនៃការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសត្រូវអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ជាពិសេសច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីសារពើពន្ធ ច្បាប់ស្ដីពីគយ និងអនុក្រឹត្យស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស សំដៅដល់នីតិវិធីគយមានលក្ខណៈសាមញ្ញដែលមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការជាអចិន្ត្រៃយ៍ជាមួយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់សេដ្ឋកិច្ចពិសេសនីមួយៗត្រូវអនុវត្តតាមឲ្យបានខ្ជាប់ខ្ជួន ។ មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចត្រូវផ្ដល់ប្រព្រឹត្តិកម្ម ឬធ្វើការផ្ទៀងផ្ទាត់លើអនុលោមភាពនានា ស្របតាមបញ្ញត្តិចំណុច ៣ ខាងក្រោមនៃនីតិវិធីគយពិសេសនេះ

ចំពោះអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ ទាំងក្នុងដំណាក់កាលសាងសង់ ក៏ដូចជាក្នុងដំណាក់កាលធ្វើអាជីវកម្ម និងផលិតកម្ម ។ ការងារនេះរួមមាន :

- ការអនុវត្តនូវសេចក្តីសម្រេចរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា អនុញ្ញាតឲ្យនាំចូលឧបករណ៍ សម្ភារៈបរិក្ខារ សម្ភារៈសំណង់សម្រាប់ការងារសាងសង់តំបន់របស់អ្នកអភិវឌ្ឍន៍តំបន់

- ការចូលរួមក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីពិនិត្យ និងសម្រេចនៅនឹងកន្លែង នូវការលើកទឹកចិត្តលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ជាតុចូលផលិតកម្មរបស់អ្នកវិនិយោគក្នុងតំបន់

- ការសម្រួលឱ្យទំនិញមួយចំនួនត្រូវបាននាំចូលដោយជំពាក់បែបបទគយ ក្នុងករណីមានភាពយឺតយ៉ាវពីការបំពេញបែបបទដោយថាហេតុនានា

- ការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ អនុលោមភាពពាក់ព័ន្ធទៅនឹងការកិច្ចនិងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ ក្នុងពេលសាងសង់ ពេលធ្វើអាជីវកម្ម ផលិតកម្ម ពេលដឹកជញ្ជូនទំនិញទៅ ឬមក មាត់ច្រកនាំចេញ មាត់ច្រកនាំចូល និងការបំពេញបែបបទគយនៅច្រកទ្វារចេញ - ចូល ឬក្នុងតំបន់ ។

### ៣. នីតិវិធីគយពិសេស

៣.១ <u>ការសាងសង់របងការពារ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៃតំបន់សេដ្ឋកិច្ចពិសេស :</u>

៣.១.១ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងជាជំហានដំបូង អ្នកអភិវឌ្ឍន៍តំបន់ត្រូវកសាងរបងព័ទ្ធជុំវិញតំបន់ដែលមានច្រកទ្វារចេញ - ចូលច្បាស់លាស់ កសាងអគារការិយាល័យចាត់ចែងការងាររបស់រដ្ឋបាលតំបន់ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់បឋមជាមុន ដើម្បីផ្តល់លទ្ធភាពដល់មន្ត្រីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសអាចប្រចាំការដោយអចិន្ត្រៃយ៍ក្នុងតំបន់នេះជាពិសេសមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ដែលមានតួនាទីសម្របសម្រួលការងារត្រួតពិនិត្យការនាំចេញ - នាំចូលនានារបស់តំបន់សេដ្ឋកិច្ចពិសេស ។

៣.១.២ ការកសាងរបងដែលរឹងមាំ ត្រូវធ្វើដោយឡែកសម្រាប់មណ្ឌលផលិតកម្ម មណ្ឌលពាណិជ្ជកម្មសេរី និងក្នុងករណីចាំបាច់ តាមគ្រប់ទីតាំងរបស់អ្នកវិនិយោគក្នុងតំបន់នីមួយៗ ។

៣.២ <u>ការធ្វើប្រតិភូកម្មអំណាចជូនតំណាងទីចាត់ការគយ និងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស</u>: នាយកទីចាត់ការគយ និងរដ្ឋាករ អាចធ្វើប្រតិភូកម្មអំណាចចាំបាច់នានាជាបន្តដល់តំណាងទីចាត់ការគយ និងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស នូវសមត្ថកិច្ចសម្រេចអនុញ្ញាតឱ្យនាំចូល ឬនាំចេញទំនិញនានារបស់តំបន់សេដ្ឋកិច្ចពិសេសទាំងនោះ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្នុងនាមទីចាត់ការគយ និងរដ្ឋាករ ។ ការធ្វើប្រតិភូកម្មអំណាចចាំបាច់នានាជាបន្ត ដល់តំណាងទីចាត់ការគយ និងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេសនីមួយៗនូវសិទ្ធិសម្រេចនានា ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចធ្វើឡើងបានក្នុងករណីមានការឯកភាព ឬមានការធ្វើប្រតិភូកម្មអំណាចជាគោលការណ៍ជូនទីចាត់ការគយ និងរដ្ឋាករ នូវអំណាចទាំងនេះជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សមត្ថកិច្ចនេះរួមមាន :

៣.២.១ ការចូលរួមសម្រេចលើបញ្ជីមេនៃមុខទំនិញដែលត្រូវផ្តល់ការលើកទឹកចិត្តពន្ធ ឬអាករនៅពេលនាំចូលជាមួយរដ្ឋបាលតំបន់ ។

៣.២.២ ការអនុញ្ញាតឱ្យដឹកជញ្ជូនទំនិញពីមាត់ច្រកព្រំដែន មកបំពេញបែបបទគយនាំចូលក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានារបស់អ្នកអភិវឌ្ឍតំបន់ ក៏ដូចជាសម្រាប់បម្រើឱ្យផលិតកម្ម ឬអាជីវកម្មរបស់វិនិយោគិនក្នុងតំបន់រួមទាំងសិទ្ធិក្នុងការអនុញ្ញាតឱ្យទំនិញ ឬសម្ភារៈនាំចូលទាំងនោះបានស្ថិតក្រោមរបបពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដោយមិនកម្រិតបរិមាណ ឬតម្លៃឡើយ លើកលែងតែករណីដែលមានវេទយិតភាពខ្ពស់ ឬភាពមិនប្រក្រតីដែលត្រូវសុំការសម្រេចជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

៣.២.៣ ការអនុញ្ញាតឱ្យបំពេញបែបបទគយនាំចេញនៅនឹងកន្លែង រួចដឹកជញ្ជូនត្រង់សំដៅទៅមាត់ច្រកព្រំដែននាំចេញ ក្រោមការឃ្លាំមើលរបស់គយ ។

៣.២.៤ ការអនុញ្ញាតឱ្យបំពេញបែបបទគយលើទំនិញ ដែលចេញពីតំបន់សេដ្ឋកិច្ចពិសេសចូលក្នុងដែនគយសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងទំនិញដែលចូលក្នុងតំបន់សេដ្ឋកិច្ចពិសេសពីដែនគយ ។

៣.២.៥ សហការជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតក្នុងករណីចាំបាច់ ដើម្បីតាមដាន និងឃ្លាំមើលជាប្រចាំនូវលទ្ធភាពនៃការរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិជាធរមានណាមួយជាយថាហេតុ ជាពិសេសពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញដែល

ទទួលបានការលើកទឹកចិត្ត សម្រាប់តំបន់សេដ្ឋកិច្ចពិសេស ចូលទីផ្សារក្នុងស្រុក ។

៣.៣ ការកំណត់ដែនគយជាតិ និងដែនគយពិសេសនៃតំបន់សេដ្ឋកិច្ចពិសេស:

៣.៣.១ ដោយមានការយោគយល់គ្នាទៅវិញទៅមកជាមួយអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ ក្នុងក្របខ័ណ្ឌនៃរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ត្រូវកំណត់នូវផ្នែកនានានៃតំបន់សេដ្ឋកិច្ចពិសេសនីមួយៗជាដែនគយពីរផ្សេងគ្នាគឺ ដែនគយជាតិ និងដែនគយពិសេស ។

៣.៣.២ ដែនគយជាតិគឺជាទីកន្លែងដែលការនាំចេញ ឬការនាំចូល ចេញពី ឬទៅក្នុងដែនគយនេះ ជាកម្មវត្ថុនៃការអនុវត្តនីតិវិធីគយជាធរមាន រួមមាន ការបំពេញបែបបទគយ កាតព្វកិច្ចពន្ធ ឬអាករ និងការទទួលបាននូវប្រព្រឹត្តិកម្ម ឬការលើកទឹកចិត្តដូចការអនុវត្តនៅទូទាំងដែនគយ ។ ដែនគយជាតិនៃតំបន់សេដ្ឋកិច្ចពិសេសអាចរួមមាន មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន មណ្ឌលទេសចរណ៍ និងមណ្ឌលសម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម និងពាណិជ្ជកម្ម និងសកម្មភាពចាំបាច់ផ្សេងៗទៀតរបស់តំបន់ ។

៣.៣.៣ ដែនគយពិសេស គឺជាទីកន្លែងដែលការនាំចេញ ឬការនាំចូល ចេញពី ឬទៅក្នុងដែនគយពិសេសនេះ ជាទូទៅអាចត្រូវបានចាត់ទុកជាបណ្តោះអាសន្នថា នៅក្រៅដែនគយជាតិ ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីគយពិសេស ទាំងក្នុងការបំពេញបែបបទគយឆាប់រហ័ស និងការទទួលបាននូវប្រព្រឹត្តិកម្មអនុគ្រោះបំផុតតាមដែលអាចធ្វើទៅបាន ។ ដែនគយពិសេសនៃតំបន់សេដ្ឋកិច្ចពិសេសអាចរួមមានតំបន់ឧស្សាហកម្មទូទៅ តំបន់ផលិតកែច្នៃនាំចេញ មណ្ឌលពាណិជ្ជកម្មសេរី និងមណ្ឌលផលិតកម្មផ្សេងៗទៀតដែលស្ថិតនៅក្នុងតំបន់ ។

៣.៤ ការសម្រួលលំហូរទំនិញ ក្នុង ចេញ និងចូល ដែនគយពិសេសនៃតំបន់សេដ្ឋកិច្ចពិសេសរបស់អ្នកវិនិយោគក្នុងតំបន់ :

៣.៤.១ សម្រាប់តំបន់សេដ្ឋកិច្ចពិសេសដែលស្ថិតនៅជិតមាត់ច្រកព្រំដែនផ្លូវគោក ឬស្ថិតនៅក្នុងរង្វង់ម្ភៃ(២០) គីឡូម៉ែត្រ នៃដែនអំណាចគយមណ្ឌលដីគោកជាប់ព្រំដែនគោក ឬតំបន់ឆ្នេរសមុទ្រ :

៣.៤.១.១ ការបង្កើតតម្រាយផ្លូវលំហូរទំនិញដោយសេរី (Seamless Route)

ក. មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ប្រចាំតំបន់សេដ្ឋកិច្ចពិសេសដូចនេះ ត្រូវពិនិត្យ និងស្នើសុំការសម្រេចពីទីចាត់ការគយ និងរដ្ឋាករ ដើម្បីកំណត់តម្រាយ

ផ្លូវលំហូរទំនិញដោយសេរីមួយ និងកំណត់រយៈពេលសមស្រប សម្រាប់ដឹកជញ្ជូនទំនិញឆ្លងកាត់ទៅ-មករវាងតំបន់សេដ្ឋកិច្ចពិសេស និងមាត់ច្រកព្រំដែនផ្លូវការដែលនៅជិតបំផុត ដោយពុំចាំបាច់តម្កល់ប្រតិវេទន៍គយនៅមាត់ច្រកព្រំដែនឡើយ ហើយគ្រាន់តែបង្ហាញ និងផ្តល់ជូននូវឯកសារចម្លងដែលពាក់ព័ន្ធនឹងទំនិញឆ្លងកាត់នេះ ។

ខ. សម្រាប់ការនាំចូល ឯកសារទាំងនេះអាចរួមមាន វិក្កយបត្រ ឯកសារដឹកជញ្ជូន ឬឯកសារផ្សេងទៀតដែលអាចបង្ហាញបាននូវទិន្នន័យទំនិញ ឬថា ទំនិញនេះត្រូវដឹកជញ្ជូនទៅតំបន់សេដ្ឋកិច្ចពិសេសនៅជិតមាត់ច្រកព្រំដែននោះ ។

គ. សម្រាប់ការនាំចេញ ឯកសារទាំងនោះអាចរួមមាន ប្រតិវេទន៍គយនាំចេញ និងឯកសារអមប្រតិវេទន៍គយផ្សេងៗទៀតដែលមានការបញ្ជាក់ពីមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំតំបន់សេដ្ឋកិច្ចពិសេសនោះ ។

៣.៤.១.២ នីតិវិធីនៅមាត់ច្រកនៃតំបន់សេដ្ឋកិច្ចពិសេសៈ

ក. អ្នកនាំចូលត្រូវតម្កល់ប្រតិវេទន៍បំពេញ ឬតម្កល់ឯកសារដែលអាចបង្ហាញនូវទិន្នន័យពាក់ព័ន្ធនឹងទំនិញដូចរៀបរាប់ខាងលើដល់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ។

ខ. មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច គ្រាន់តែផ្ទៀងផ្ទាត់បឋមនូវអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ មធ្យោបាយដឹកជញ្ជូន និងឯកសារពាក់ព័ន្ធ រួចអនុញ្ញាតឱ្យទំនិញឆ្លងចូលទៅក្នុងអាជីវកម្មដ្ឋានរបស់អ្នកវិនិយោគក្នុងតំបន់ដែលពាក់ព័ន្ធ ឬទីតាំងផ្សេងទៀតនៃតំបន់សេដ្ឋកិច្ចពិសេស ប្រសិនបើអ្នកវិនិយោគពុំមានទីតាំងសមស្របសម្រាប់ទទួលទំនិញនេះ ។

គ. អ្នកនាំចូលអាចចាត់ចែងពីទំនិញរបស់ខ្លួន ដើម្បីប្រើប្រាស់ ឬកែច្នៃតាមតម្រូវការនៃការវិនិយោគរបស់ខ្លួនបាន ដោយពុំចាំបាច់មានវត្តមានរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចឡើយ លើកលែងតែមានការតម្រូវជាពិសេស ពីមន្ត្រីទាំងនេះ ដើម្បីធ្វើការត្រួតពិនិត្យរូបវន្តលើទំនិញ ស្របតាមគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងដោយមានការអនុញ្ញាតជាមុនពីតំណាងទីចាត់ការគយ និងរដ្ឋាករប្រចាំតំបន់ ។

ឃ. ក្រោយពេលពីទំនិញរួចភ្លាម អ្នកនាំចូលត្រូវតម្កល់ប្រតិវេទន៍គយលម្អិតជូនមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ដោយមានភ្ជាប់បញ្ជីលម្អិតមុខទំនិញ

ដែលមាន ឬគ្មានក្នុងបញ្ជីមេដែលមានការឯកភាពពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

ង. មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ត្រូវគ្រប់គ្រង កាត់កងចេញពីបញ្ជីមេនូវមុខទំនិញដែលបានប្រកាសខាងលើ ។ ចំពោះមុខទំនិញដែលគ្មានក្នុងបញ្ជីមេ តែស្ថិតក្នុងមុខសញ្ញាត្រូវលើកទឹកចិត្តស្របតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនោះ មន្ត្រីតំណាងទីចាត់ការគយ និងរដ្ឋាករប្រចាំតំបន់ មានសិទ្ធិអនុញ្ញាតឱ្យនាំចូលដោយជំពាក់បែបបទគយនៅនឹងកន្លែង ប្រសិនបើមានការស្នើសុំដូចនេះពីអ្នកវិនិយោគក្នុងតំបន់ ។ ចំពោះមុខទំនិញផ្សេងទៀតដែលមិនស្ថិតក្នុងមុខសញ្ញាលើកទឹកចិត្តដូចរៀបរាប់ខាងលើនេះ គឺជាកម្មវត្ថុនៃការអនុវត្តតាមនីតិវិធីគយជាធរមាន ជាពិសេសពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចពន្ធ និងអាករ និងការជាប់កម្រិតកំណត់ផ្សេងៗ ។

ច. ចំពោះការនាំចេញទំនិញដោយត្រង់ទៅបរទេស បែបបទគយនាំចេញត្រូវបំពេញនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសតាមនីតិវិធីគយជាធរមាន ។ ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចត្រូវអនុញ្ញាតឱ្យទំនិញបាននាំចេញជាបន្ទាន់ ដោយអមភ្ជាប់នូវច្បាប់ចម្លងនៃឯកសារនាំចេញ សម្រាប់បង្ហាញជូនមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកព្រំដែន ។ មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកព្រំដែនត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃមធ្យោបាយដឹកជញ្ជូន និងឯកសារពាក់ព័ន្ធនឹងការនាំចេញ ហើយអនុញ្ញាតឱ្យទំនិញបាននាំចេញជាបន្ទាន់ ប្រសិនបើពុំមានភាពមិនប្រក្រតី ។

៣.៤.១.៣ ការនាំចេញ ឬនាំចូលទំនិញ របស់តំបន់សេដ្ឋកិច្ចពិសេសប្រភេទនេះ ដោយប្រើប្រាស់មាត់ច្រកនាំចេញ ឬនាំចូលដែលពុំស្ថិតនៅជិតបំផុតពីតំបន់ដែលភ្ជាប់ដោយតម្រាយផ្លូវលំហូរទំនិញដោយសេរី : ត្រូវអនុវត្តតាមនីតិវិធីនៃចំណុច ៣.៤.២ ខាងក្រោម ។

៣.៤.២ សម្រាប់តំបន់សេដ្ឋកិច្ចពិសេសដែលមិនស្ថិតនៅជិតមាត់ច្រកព្រំដែនផ្លូវការ ឬមិនស្ថិតនៅក្នុងរង្វង់ម្ភៃ(២០) គីឡូម៉ែត្រ នៃវង់អំណាចគយមណ្ឌលដីគោកជាប់ព្រំដែនគោក ឬតំបន់ឆ្នេរសមុទ្រ :

៣.៤.២.១ នីតិវិធីគយនៅមាត់ច្រកនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃចំណុច ៣.៤.១.២ ខាងលើ ។

៣.៤.២.២ ការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅ - មករវាងតំបន់សេដ្ឋកិច្ចពិសេស និងមាត់ច្រកព្រំដែនផ្លូវការនានា :

ក. ចំពោះការនាំចូល :

- អ្នកវិនិយោគក្នុងតំបន់ត្រូវស្នើសុំជាលាយល័ក្ខណ៍អក្សរទៅការិយាល័យ ឬទីស្នាក់ការគយ និងរដ្ឋាករមាត់ច្រកព្រំដែនដែលទំនិញរបស់ខ្លួនត្រូវបាននាំចូល ដើម្បីសុំការអនុញ្ញាតដឹកជញ្ជូនទំនិញឆ្លងកាត់ពីមាត់ច្រកនាំចូលនានាមកតំបន់សេដ្ឋកិច្ចពិសេស ដែលខ្លួនប្រកបអាជីវកម្មក្រោមរបបគយឆ្លងកាត់ ។ សំណើសុំដែលមានការបញ្ជាក់ទទួលស្គាល់ពីមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំតំបន់សេដ្ឋកិច្ចពិសេសត្រូវតម្កល់ជូនមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការិយាល័យ ឬទីស្នាក់ការគយ និងរដ្ឋាករមាត់ច្រកព្រំដែនដោយអមភ្ជាប់ជាមួយប្រតិវេទន៍គយឆ្លងកាត់និងឯកសារពាក់ព័ន្ធនានា។

- មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការិយាល័យ ឬទីស្នាក់ការគយនិងរដ្ឋាករមាត់ច្រកព្រំដែនត្រូវផ្តល់អាទិភាពក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់បែបបទគយឆ្លងកាត់តាមសំណើសុំនេះ និងអនុញ្ញាតឱ្យដឹកជញ្ជូនទំនិញទាំងនេះឆ្លងកាត់មកកាន់តំបន់សេដ្ឋកិច្ចពិសេសជាបន្ទាន់ដោយគ្រាន់តែកិបសៀលគយ និងអមភ្ជាប់ដោយឯកសារពាក់ព័ន្ធតាមនីតិវិធីគយឆ្លងកាត់ជាធរមាន ។ ក្នុងករណីដែលការដឹកជញ្ជូននោះពុំអាចកិបសៀលគយបានប្រកបដោយប្រសិទ្ធភាពនោះ ដូចជាទំនិញមិនផ្ទុកក្នុងកុងតេន័រជាដើមនោះ មន្ត្រីគយ និងរដ្ឋាករមានសម្ថកិច្ចនាមាត់ច្រកព្រំដែនត្រូវសហការគ្នាបង្កើតយន្តការអមទំនិញ ឬឃ្លាំមើលទំនិញទាំងនេះ ។

ខ. ចំពោះការនាំចេញ :

- ចំពោះការនាំចេញទំនិញដោយត្រង់ទៅបរទេស បែបបទគយនាំចេញត្រូវបំពេញនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសតាមនីតិវិធីគយជាធរមាន ។ ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចត្រូវអនុញ្ញាតឱ្យទំនិញបាននាំចេញជាបន្ទាន់ដោយគ្រាន់តែកិបសៀលគយ និងដោយអមភ្ជាប់នូវច្បាប់ចម្លងនៃឯកសារនាំចេញពាក់ព័ន្ធតាមនីតិវិធីគយជាធរមានសម្រាប់បង្ហាញជូនមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកព្រំដែន ។ ចំពោះទំនិញដែលមិនផ្ទុកក្នុងកុងតេន័រត្រូវតែស្ថិតក្រោមយន្តការឃ្លាំមើលដូចរៀបរាប់ខាងលើផងដែរ ។

៣.៥ <u>នីតិវិធីផ្សេងទៀតពាក់ព័ន្ធនឹងការហាមឃាត់ និងការដាក់កម្រិតកំណត់ផ្សេងៗ :</u>

៣.៥.១ ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតនាំចូលពីបរទេស ឬយកចូលពីដែនគយជាតិដែលមានចែងក្នុងបញ្ជីមេ និងដែលចេញដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬពីស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតពុំតម្រូវឱ្យមានលិខិតអនុញ្ញាតអ្វីទៀតឡើយ លើកលែងតែជាប្រភេទទំនិញដែលហាមឃាត់ដាច់ខាតក្នុងការនាំចូលឬនាំចេញស្របតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ឬប្រភេទមានហានិភ័យខ្ពស់បំផុតដល់សុវត្ថិភាពសាធារណៈ ។

៣.៥.២ ផលិតកម្មទំនិញក្លែងក្លាយ ដែលអាចប៉ះពាល់កម្មសិទ្ធិបញ្ញា ភាពផ្តាច់មុខ ដើមកំណើតទំនិញឬការកម្រិតកំណត់ផ្សេងទៀតពាក់ព័ន្ធនឹងវិធានគុណភាព និងស្តង់ដារផលិតកម្មជាកម្មវត្ថុនៃការអនុវត្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

៣.៥.៣ វិធានការពិសេសដូចមានចែងក្នុងបញ្ញត្តិជំពូកទី ៥ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ជាពិសេសពាក់ព័ន្ធនឹងការលក់ទំនិញចូលទីផ្សារក្នុងស្រុក ឬប្រើប្រាស់ក្នុងដែនគយជាតិនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តស្របគ្នាជាមួយនឹងនីតិវិធីគយពិសេសនេះសម្រាប់គោលបំណងនៃការគ្រប់គ្រង ការឃ្លាំមើល និងការត្រួតពិនិត្យអនុលោមភាពនៃប្រតិបត្តិការនានាក្នុងតំបន់សេដ្ឋកិច្ចពិសេសជារួម ។